# អានិសង្សទៀនព្រះវស្សា

ក្នុងព្រះពុទ្ធសាសនា "ចូលព្រះវស្សា" ជាពុទ្ធបញ្ញត្តិមានចែងក្នុងវិន័យបិដកភាគ៧ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ឱ្យព្រះភិក្ខុគង់ចាំព្រះវស្សា៣ខែ។ ព្រះបរមគ្រូទ្រង់បញ្ញត្តិមកដូច្នោះ ព្រោះមានមូលហេតុពីរយ៉ាងគឺ (១)ព្រះភិក្ខុទាំងឡាយត្រាច់ចរទៅកាន់ទីកន្លែងជិតឆ្ងាយ មានកន្លែងសមគួរខ្លះមិនសមគួរខ្លះ មាននិមន្តជាន់លើភូតគាមពិជគាម និងធញ្ញជាតិផ្សេងៗជាហេតុនាំឱ្យអ្នកស្រុករិះគន់ និងពោលនូវទោសដល់ព្រះភិក្ខុសង្ឃ។ (២) ព្រះពុទ្ធអង្គមានបំណងអនុគ្រោះព្រះភិក្ខុសង្ឃក្នុងសាសនានេះកុំឱ្យលំបាកធ្វើដំណើរក្នុងរដូវវស្សាដែលមានភ្លៀងធ្លាក់ជោកជាំ។[1] បើពោលជាទំនៀមព្រះពុទ្ធសាសនា ការចូលវស្សាមានពីរយ៉ាងគឺ (១) "បុរិមិកាវស្សា" ការចូលវស្សាដំបូង ចាប់ពីថ្ងៃ១រោច ខែអាសាឍ[2] ដល់គ្រប់១ត្រីមាស(៣ខែ) ទើបចេញវស្សានៅថ្ងៃ១៥កើត ខែអស្សុជ។ (២) "បច្ឆិមិកាវស្សា" ជាការចូលវស្សាលើកក្រោយ[3] ពោលគឺចាប់ពីថ្ងៃ១រោច ខែស្រាពណ៍ ដល់ថ្ងៃ១៥កើត ខែកត្តិក ទើបត្រូវចេញវស្សា។ ការចូលវស្សាលើកក្រោយនេះ ព្រះពុទ្ធទ្រង់អនុញ្ញាតដល់ភិក្ខុសង្ឃមានកិច្ចរវល់ដោយប្រការណាមួយ ដែលពុំអាចចូលវស្សាទី១។ ចំពោះបុណ្យចូលព្រះវស្សាឆ្នាំនេះនឹងចូលនៅថ្ងៃព្រហស្បតិ៍ ១រោច ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០ ត្រូវនឹងថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៦។

ទន្ទឹមនឹងសេចក្តីជាពុទ្ធបញ្ញត្តិមកខាងលើ ក្នុងបុណ្យចូលព្រះវស្សានៃសង្គមខ្មែរគេសង្កេតឃើញមានវត្ថុជាគ្រឿងបូជាយ៉ាងសំខាន់បំផុតគឺ "ទៀនវស្សា"។[4] សោតឯទៀននោះបើតាមទំនៀមនិទានពីបុរាណ គឺតែងកើតឡើងពីសទ្ធាពុទ្ធបរិស័ទរួមសាមគ្គីគ្នា រិះគិតរកក្រមួន ដើម្បីយកមកសូសិតស្អិតស្អាងឱ្យកើតជាទៀន តាំងពីមុនថ្ងៃចូលវស្សាមកដល់។ មិនតែប៉ុណ្ណោះបើយោងតាមឯកសារព្រះរាជពិធីទ្វាទសមាស និងឯកសារមហាសង្ក្រាន្តឱ្យដឹងថា ទំនៀមសិតទៀនព្រះវស្សាតែងប្រារព្ធឡើងទាំងនៅក្នុងព្រះបរមរាជវាំង និងនៅ

---

[1] ព្រះវិន័យបិដក ភាគ២, លេខ៧, ទំ.១-៦៥

[2] បើឆ្នាំណាលើកខែអាសាឍពីរដង ត្រូវចូលវស្សានៅថ្ងៃ១រោច ខែទុតិយាសាឍ។

[3] ក្រោយថ្ងៃចូលវស្សាលើកដំបូងចំនួន១ខែ។

[4] ខ្លះហៅថាទៀនព្រះវស្សា ឬខ្លះទៀតហៅថា ទៀនចំណាំព្រះវស្សា។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

តាមវត្តអារាមនានាផង។ ទំនៀមសិតទៀននេះ គឺយកក្រមួនមកស្ងោរឱ្យរលាយរាវជាទឹក ហើយចាក់ដាក់ពុម្ពធ្វើជាទៀន។ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ស្ដេចយាងចេញធ្វើព្រះរាជកុសលផ្ទាល់ព្រះអង្គ ដោយជួបជុំព្រះរាជវង្សានុវង្ស គណរដ្ឋមន្ត្រី ព្រមទាំងនាហ្មឺនសព្វមុខមន្ត្រីទាំងឡាយ។ ព្រះរាជពិធីសិតទៀនវស្សាព្រះរាជទ្រព្យ ក៏ឃើញមានឯកសារព្រះឆាយាលក្ខណ៍ **ព្រះមហាក្សត្រីយានី ស៊ីសុវត្ថិ មុនីវង្ស កុសុមៈនារីរតន៍សិរីវឌ្ឍនា** ស្ដេចយាងសិតទៀនព្រះវស្សាបន្តរហូតមកដល់ **ព្រះករុណាព្រះមហាក្សត្រ** បច្ចុប្បន្ន (រូបលេខ១-២)។



រូបលេខ១-២ ព្រះឆាយាលក្ខណ៍ ***ព្រះមហាក្សត្រីយានី ស៊ីសុវត្ថិ មុនីវង្ស កុសុមៈនារីរតន៍ សិរីវឌ្ឍនា*** និង ***ព្រះករុណាព្រះមហាក្សត្រ*** ស្ដេចយាងសិតទៀនព្រះវស្សាព្រះរាជទ្រព្យ (រូប៖ Royal du Cambodge)

ពាក់ព័ន្ធទំនៀមព្រះរាជពិធីសិតទៀនព្រះវស្សាជាព្រះរាជទ្រព្យ និងពិធីសិតទៀនព្រះវស្សារបស់បណ្ដារាស្ត្រសាមញ្ញ បុរាណលោកកំណត់យកក្នុងខែអាសាឍ ពោលគឺសិតទៀននៅថ្ងៃ៨កើត ដង្ហែទៀនដាក់វត្តនៅថ្ងៃ១៤កើត ហើយប្រារព្ធធ្វើពិធីបុណ្យចូលព្រះវស្សានៅថ្ងៃ១រោច។[5] ប៉ុន្តែទំនៀមអ្នកស្រុកខ្លះ លោកតែងមូលមាត់គ្នារៀបចំសិតទៀនព្រះវស្សាតាំងពីមុនថ្ងៃ៨រោចក៏សឹងមាន។ ជាក់ស្ដែងគេឃើញទំនៀមសិតទៀនព្រះវស្សានៅវត្តកោះប៉ែន ស្ថិតក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម អ្នកស្រុកតែងនាំគ្នាប្រារព្ធពិធី

[5] ចាប ពិន, ១៩៦៥, ទំ. ៤ និង ព្រហ្ម វីរៈ, ១៩៦៤, ទំ. ២១

សិតទៀនវស្សាតាំងពីមុនថ្ងៃ៨រោច ខែអាសាឍ។ ក្នុងវត្តនេះតែងសិតទៀនជាច្រើនដើម ហើយឆ្នាំខ្លះសិតទៀនរហូតដល់២០ដើម ដើម្បីដង្ហែប្រគេនវត្តផ្សេងៗជុំវិញ។ ទន្ទឹមនោះ ពុទ្ធបរិស័ទតែងបូជាប្រេង និងទេយ្យទានផ្សេងៗផងដែរ (រូបលេខ៣-៦)។



រូបលេខ៣-៦ ពុទ្ធបរិស័ទមានសទ្ធាជ្រះថ្លាសិតទៀនព្រះវស្សា និងប្រគេនប្រេង ព្រមទាំងទេយ្យប្រគេនព្រះសង្ឃសម្រាប់គង់ចាំព្រះវស្សា នៅវត្តកោះប៉ែន ខេត្តកំពង់ចាម

KHMER CIVILIZATION

ចំណែកខ្នាតទៀនវស្សា តាមឯកសារព្រះរាជពិធីទ្វាទសមាសបញ្ជាក់ថា ទៀនមាន ២ខ្នាតគឺ ខ្នាតតូចទំហំ២ចាប់ ខ្នាតធំទំហំ២ចាប់កន្លះ និងកម្ពស់២ហត្ថដូចគ្នា។[6] រីឯសេចក្តីសង្កេតរបស់អ្នកស្រី ពេជ្រ សល់ ថាទៀនវស្សាធម្មតាមានទទឹងមាត់មួយតឹក និងកម្ពស់២ហត្ថ ធ្វើពីក្រមួនឃ្មុំ ឬក្រមួនចំបក់។[7] លុះទៀនទាំងឡាយសិតបានស្រេចបរិបូរណ៍ហើយ បើជាទៀនព្រះវស្សាព្រះរាជទ្រព្យ ទ្រង់ចាត់ព្រះរាជតំណាងដង្ហែទៅកាន់វត្តក្នុងរាជធានី

[6] ចាប ពិន ១៩៦០: ៦

[7] ពេជ្រ សល់ ១៩៧៣: ២៣១-២៣២

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

និងនៅវត្តតាមខេត្តដែលទ្រង់មានព្រះរាជសទ្ធាថ្វាយ(រូបលេខ៧-៩)។ ក្នុងប្រពៃណីខ្មែរជាទូទៅគេសង្កេតឃើញព្រះសង្ឃតែងអុជទៀនវស្សាទាំងនោះ បូជានៅក្នុងព្រះវិហារ ឬនៅលើសាលាឆាន់ពេញមួយរដូវចូលវស្សារយៈពេល៣ខែ ដូចពោលមកពីខាងដើម។








រូបលេខ៧-៩ ព្រះរាជពិធីដង្ហែទៀនវស្សាព្រះរាជទ្រព្យថ្វាយតាមបណ្ដាវត្ត និងគំនូរទំនៀមដង្ហែទៀនវស្សា គូរផ្សាយក្នុងឯកសារមហាសង្ក្រាន្ត

ចិត្តសទ្ធាបូជាទៀនវស្សាដូចបានរៀបរាប់មកពីខាងដើម ក៏ឃើញមានចែងអំពីផលអានិសង្ស ដែលពុទ្ធបរិស័ទខ្មែរតែងជឿជាក់តមកពីដូនតារហូតចារនៅក្នុងសាស្ត្រាទេសន៍ផង។ សេចក្ដីក្នុងសាស្ត្រាចុះលេខ FEMC105 ចារឆ្នាំ១៩២២ មានប្រភពពីខេត្តកណ្ដាល

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

បានលើកនិទានមួយឱ្យដឹងថា ការបូជាទៀនវស្សាបានអានិសង្ស៨កោដិ តាមតែប្រាថ្នាអ្វីសឹងបានដូចសេចក្ដីប្រាថ្នាទាំងអស់។ សេចក្ដីនេះមានក្នុងរឿងបុរសកំសត់រកស៊ីកាប់អុស ហើយរើសយកអាចម៍ខ្លាឃ្មុំស្វយកក្រមួន លញ់ធ្វើទៀនថ្វាយព្រះដ៏មានបុណ្យ។ ដោយអំណាចបុណ្យរបស់បុរសនោះ ព្រះឥន្ទ្រាធិរាជក៏ជប់ប្រាសាទប្រាក់ ឃ្លាំងមាស ឃ្លាំងប្រាក់ ព្រមទាំងសួនប្រកបដោយដើមឈើ ពេញដោយផ្លែផ្កាសម្បូរហូរហៀរ មានទាំងអ្នកគាល់បម្រើពុំមានខ្វះអ្វីឡើយ (រូបលេខ១០)។[8]



*រូបលេខ១០ ផ្នែកដំបូងនៃសាស្ត្រាអានិសង្សទៀនព្រះវស្សា*

ផលអានិសង្សទៀន ដែលបុរសកំសត់បានសាងទៀនព្រះវស្សានោះ បើកើតជាទេវតានឹងមានបរិវារ១លាន បើកើតជាសេដ្ឋីនោះ៥០០ជាតិ បើកើតជាស្ដេច៦ជាតិ។ អំណាចផលបុណ្យនៃបុរសនោះ បានក្ដៅដល់ស្ថានត្រៃត្រឹង្សសួគ៌នាយ នៃសម្ដេចព្រះឥន្ទ្រាធិរាជទ្រង់ព្រះចិន្តាពិចារណាថាអនាគតជាតិ បុរសនោះនឹងបានត្រាស់ជាព្រះពុទ្ធអង្គស្រង់សត្វផងទាំងឡាយដាក់ដល់ត្រើយអម្រឹតបុរីស្រីមហានគរពុំលែងឡើយ ទើបទូលប្រើព្រះវិស្វកម្មទេវតា ព្រះពិស្ណុការចុះមកស្ថាងប្រាសាទទាំង៥ ដ៏មានកំពែង៧ល្វែងចិញ្ចែងចិញ្ចាចត្រដាចត្រដឹម មានទ្វារឡប់ឡែផ្ដែរជញ្ជាំង មានឃ្លាំងមាសឃ្លាំងប្រាក់ មានឧទ្យានមានស្រះប្រកបដោយមច្ឆាទាំងឡាយមាន ផ្ទង់ ពោរ សណ្ដាយ ខ្លាំងហាយ ខ្លាំងហាត អណ្ដាត ឆ្កែ ឆ្កោក ត្រីឆ្លាម ព្រួលព្រា កំពឹស ឫសចេក ព្រោន បង្កង អណ្ដើកសរសៃ កន្ធាយល្មិច

---

[8] សូមអានសាស្ត្រាអានិសង្សទៀនវស្សា ចុះលេខ FEMC105

លៀស ខ្ទៅ គ្រែង គ្រំ ខ្យងហៀន ខ្យងហោង ត្រីក្របី សឹងហែបហែល និងពោរពាសដោយសព្វដើមឈើ ស្រង់ក្លិនផ្កាគន្ធា ផ្លែផ្ការុះរោយ មានដើមមង្ឃុត ល្មុតសេដា ម៉ាក់ប្រេងម៉ាក់ប្រាង ម៉ាកសាង ម៉ាក់ដោក ធុរេន ស្វា កន្ទួតព្រៃកន្ទួតស្រុក ផ្លែដូចគេយកទៅចងព្យួរជារំយោលសំយុង មានទាំងដើមផ្កាម្ទិះរួតម្ទិះលាចម្បាន្ទួនស្រី បាឡីកន្ទិល ក្រហមចងសក់ក្ងាំពាក់ក្ងាំពា យុថ្កា មហាហង្ស ត្រយ៉ងពុកជាជ្រុង សិងតែឈើក្រអូបតជាថ្នាំទម្លាក់រោគផឹកធីជាថ្នាំទាស់ហាល់ហត់ខ្យល់ចាប់ ហើយមានទាំងច្បារស្វាយចម្ងាយ៣០យោជន៍។

ទោះជាតាមសេចក្តីក្នុងសាស្ត្រាខាងលើបានអានិសង្សដូច្នោះក្តី គេដឹងថាក្នុងពុទ្ធបញ្ញត្តិពុំបានចែងអំពីទៀនវស្សាឡើយ តែសូមយល់ថានៅក្នុងអារ្យធម៌ខ្មែរ ការសាងនូវកុសលដោយសទ្ធាជ្រះថ្លារមែងបានផល្វានិសង្សក្រៃលែង។ ចំពោះបើនិយាយអំពី "ទៀន" ជាទូទៅគឺពុំមែនត្រឹមតែជាវត្ថុសម្រាប់អុជបំភ្លឺធម្មតាទេ តែជាគ្រឿងសក្ការបូជាដែលមានន័យទាក់ទងនឹងពាក្យថា "ទេព" (Divinity) ទាក់ទងនឹងគំនិតថា "ពន្លឺ"ៗ[៩] មិនតែប៉ុណ្ណោះនៅក្នុងគំនិតតំណាងនូវសេចក្តីចេះដឹង និងបញ្ញាញាណ ខ្មែរតែងយកទៀនជានិមិត្តរូបតំណាងដែរ។

សរុបសេចក្តីមក ទោះបីជាការសិតនិងការបូជាទៀនព្រះវស្សា ពុំមែនជាពុទ្ធបញ្ញត្តិចែងក្នុងព្រះវិន័យបិដក ដូចការចូលព្រះវស្សាយ៉ាងណាក្តី ប៉ុន្តែនៅក្នុងបរិបទសង្គម និងអរិយធម៌ខ្មែរពិធីសិតទៀន និងដង្ហែទៀនព្រះវស្សា ទាំងក្នុងព្រះបរមរាជវាំង និងតាមវត្តអារាមនានាបានក្លាយជាប្រពៃណីសាសនាដ៏មានឫសគល់ជ្រាលជ្រៅ ដែលស្តែងចេញពីកម្លាំងសទ្ធា និងសាមគ្គីភាពរបស់ពុទ្ធបរិស័ទ។ ជំនឿលើផលអានិសង្សដ៏ក្រៃលែងដូចមានចារក្នុងសាស្ត្រាស្លឹករឹតបុរាណ ពុំត្រឹមតែជាគ្រឿងលើកទឹកចិត្តឱ្យសាសនិកសាងអំពើល្អ និងទំនុកបម្រុងព្រះសង្ឃក្នុងរដូវវស្សាប៉ុណ្ណោះទេ តែបានឆ្លុះបញ្ចាំងពីទស្សនវិជ្ជាខ្មែរយ៉ាងស៊ីជម្រៅ ដែលលើកតម្កើង "ទៀន" ជានិមិត្តរូបនៃពន្លឺ ទេព និងបញ្ញាញាណ ក្នុងការបំភ្លឺផ្លូវជីវិត និងការថែរក្សាអត្តសញ្ញាណវប្បធម៌ជាតិឱ្យស្ថិតស្ថេរចីរកាល៕

[៩] អាំង ជូលាន, ២០០៨-២០០៩, ទំ.១៣-១៦

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ចាប ពិន

១៩៦០, *ព្រះរាជពិធីទ្វាទសមាស ភាគ៣*, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ពេជ្រ សល់

១៩៧៣, "ពិធីចូលព្រះវស្សា", *កម្ពុជសុរិយា*, លេខ៥, ទំ. ២២៩-២៣៥, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ព្រហ្ម វីរៈ

១៩៦៤, *មហាសង្ក្រាន្តឆ្នាំរោង ឆស័ក អធិកមាស ព.ស.២៥០៧ គ.ស. ១៩៦៤*, (?), ភ្នំពេញ

អាំង ជូលាន

២០០៨-២០០៩, "ទៀន", *កម្រងអត្ថបទក្នុងបណ្តាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ២, ទំ.១៣-១៦, Friends of Khmer Culture, ភ្នំពេញ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត